របាយការណ៍សង្ខេប
ស្តីពី
លទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ
និងអគ្គលេខាធិការដ្ឋាន
អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែឧសភា ឆ្នាំ២០២០

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

ដោយ ឯកឧត្តម **ឈឹម យិនដាវ៉ែត**
អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

មាតិកា

១. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២. សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំខែកុម្ភៈ

៤. បញ្ហា និងភាពប្រឈម

៥. ជំហានបន្តសម្រាប់ខែបន្ទាប់

១. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការងារមូលនិធិសកល :

- ថ្ងៃ១០ ខែមិថុនា ពីម៉ោង ៦: ៣០នាទី ដល់ម៉ោង៧: ៣០នាទីយប់ ចូលរួមប្រជុំស្តាប់របាយការណ៍អំពីបច្ចុប្បន្នភាពនៃការប្រយុទ្ធនឹងCOVID-19 និងការពង្រីកប្រព័ន្ធ Wamboo ដល់កម្មវិធីដែលមិនប្រើប្រាស់ថវិកាមូលនិធិសកល ដោយអគ្គនាយក Peter Sands។
- ថ្ងៃ១១ ខែមិថុនា បានចូលរួមប្រជុំស្តាប់របាយការណ៍របស់លេខាធិការដ្ឋានមូលនិធិសកលអំពី- ក្រុមប្រណិបត្តិនៃមន្ត្រីអភិបាលកិច្ច ដែលបានធ្វើវិសោធនកម្ម និង កែសម្រួលឡើងវិញ - គោលនយោបាយទំនាស់ផលប្រយោជន៍ដែលបានធ្វើវិសោធនកម្ម និង កែសម្រួលឡើងវិញ - ការកែសម្រួលឡើងវិញនូវសូចនាករ 6a 6f 9c 12b។

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការងារមូលនិធិសកល (ត)

- ថ្ងៃ១៧ ខែមិថុនា ពីម៉ោង ៦: ៣០ ដល់ ៧:៣០ យប់ បានចូលប្រជុំស្តាប់របាយការណ៍របស់អគ្គនាយក Peter Sands អំពីបច្ចុប្បន្នភាពនៃការប្រយុទ្ធនឹង COVID-19 ។
- ថ្ងៃ១៩ ខែមិថុនា ពីម៉ោង ៨:00 ដល់ម៉ោង៩:00 យប់ ចូលរួមប្រជុំក្រុមអ្នកអនុវត្តកម្មវិធីជាមួយថ្នាក់ដឹកនាំក្រុមប្រឹក្សាមូលនិធិសកល ដើម្បីចែករំលែកបទពិសោធន៍អំពីការប្រយុទ្ធនឹ Covid-19 នៅអាហ្វ្រិកខាងលិច កណ្តាល ខាងកើត និង ខាងត្បូង នៅអាមេរិកឡាទីន ការីប៊ាន អឺរ៉ុបខាងកើត និងនៅអាស៊ីកណ្តាល ។
- ថ្ងៃទី ២៥ មិថុនា ចាប់ពីម៉ោង ៦:៣០ នាទីយប់ បានអញ្ជើញចូលរួមចូលរួមប្រជុំតាមប្រព័ន្ធvdo conference ជាមួយថ្នាក់ដឹកនាំថ្មីនៃគណៈកម្មាធិការយុទ្ធសាស្ត្ររបស់មូលនិធិសកល ។

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការងារ អ.ជ.ប.ជ.អ :

- ថ្ងៃទី១៧ មិថុនា ២០២០ បានអញ្ជើញចូលរួមបើកឯកសារដេញថ្លៃស្តីអំពីការផ្គត់ផ្គង់ ការបោះពុម្ព សៀវភៅអំពីវិស័យអេដស៍ ជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០២០។
- ថ្ងៃទី២៥ ខែមិថុនា ឯកឧត្តមទេសរដ្ឋមន្ត្រី បានអញ្ជើញចូលរួមពិធីបើកឯកសារពិគ្រោះថ្លៃស្តីអំពី ការផ្គត់ផ្គង់ប្រេងឥន្ធៈ ឆ្នាំ២០២០។
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានពិនិត្យ និងសម្រេចលើសកម្មភាពនានារបស់ អ.ជ.ប.ជ.អ។
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានជួបប្រជុំពិភាក្សាការងារបច្ចេកទេសជាមួយថ្នាក់ដឹកនាំរបស់អ.ជ.ប.ជ .អ និងបានផ្តល់អនុសាសន៍ពីនិតិវិធីឆ្លើយតបនឹងមេរោគអេដស៍ និងព្រមទាំងលើកទិសដៅ ផែនការសកម្មភាពរបស់ អ.ជ.ប.ជ.អ។

ឯកឧត្តមទេសរដ្ឋមន្ត្រី

៣- ការងារនៅទីស្តីការគណៈរដ្ឋមន្ត្រី :

- ឯកឧត្តមទេសរដ្ឋមន្ត្រី បានអញ្ជើញចូលរួមប្រជុំប្រចាំសប្តាហ៍នៅទីស្តីការគណៈរដ្ឋមន្ត្រី។
- ថ្ងៃទី២៤ មិថុនា ២០២០ បានអញ្ជើញចូលរួមពិធីប្រកាសជាផ្លូវការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩ នៅវិមានសន្តិភាព។
- **៤- ការងារនៅមូលដ្ឋាន** :
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានតាមដាន និងណែនាំឱ្យមន្ត្រីខុទ្ទកាល័យ ទំនាក់ទំនងសួរសុខទុក្ខពីសុខភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងស្ថានភាពការងាររបស់ប្រជាពលរដ្ឋតាមភូមិ ជាពិសេស ពលករចំណាកស្រុកមកពីខាងក្រៅប្រទេស តាមរយៈមេឃុំ និងប្រធានភូមិ។

ឯកឧត្តម គង់ រដ្ឋា

- ពិនិត្យ ផ្តល់យោបល់ ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ការងារផ្ទៃក្នុងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីនិរន្តភាពនៃដំណើរការផ្ទៃក្នុង អ.ជ.ប.ជ.អ។

ឯកឧត្តម ជា ផលា

១- ការដាក់បញ្ចូលការងារឆ្លើយតបនឹងមេរោគអេដស៍នៅក្នុងឃុំ

- ពិភាក្សាជាមួយមន្ត្រីបច្ចេកទេសនិងទាក់ទងដៃគូពាក់ព័ន្ធ(HACC Buddhism for health និងUNAIDS ក្រុមប្រឹក្សាឃុំ) ដើម្បីរៀបចំទស្សនកិច្ចនៅខេត្តបាត់ដំបង។
- ធ្វើទស្សនកិច្ចសិក្សាជាមួយតំណាងអង្គការ UNAIDS នៅសង្កាត់ទួលតាឯក ឃុំជ្រៃ ឃុំក្តុលដូនទាវ នៃខេត្តបាត់ដំបង ដែលទទួលបានការគាំទ្រសម្របសម្រួលដោយអង្គការBuddhism for health ក្នុងការដាក់បញ្ចូលការងារឆ្លើយតបនឹងមេរោគ អេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/ សង្កាត់។
- ពិភាក្សាជាមួយ ឯកឧត្តម **រស់សីលវ៉ាត់** និងមន្ត្រីបច្ចេកទេស រៀបចំឯកសារគោលសម្រាប់វគ្គណែនាំបញ្ចូលការងារឆ្លើយតបនឹងមេរោគអេដស៍នៅក្នុងឃុំ៖
  - ✓ជំនាញទន់: គោលការណ៍មូលដ្ឋានទាំង៧របស់វគ្គ
  - ✓ជំនាញរឹង:ស្ថានភាពអន្តរាគមន៍និងម៉ាទ្រីចគណនាថវិកា

ឯកឧត្តម ជា ផលា

១- ការដាក់បញ្ចូលការងារឆ្លើយតបនឹងមេរោគអេដស៍នៅក្នុងឃុំ (ត)

- ដឹកនាំវគ្គណែះបណ្តាលមន្ត្រីអ.ជ.ប.ជ.អ លើជំនាញទន់ស្តីអំពីគោលការណ៍មូលដ្ឋាននៃការងារឆ្លើយតបនឹងមេរោគអេដស៍នៅថ្នាក់ឃុំ។
- ដឹកនាំមន្ត្រី អ.ជ.ប.ជ.អ ទៅបណ្តុះបណ្តាលការដាក់បញ្ចូលការងារឆ្លើយតបនឹងមេរោគអេដស៍នៅក្នុងឃុំ៥(ឃុំដូង ឃុំឆ្នោតឃុំត្រពាំងក្រសាំងឃុំក្រាំងធ្នង់ និងឃុំពត់សរ) នៅស្រុកបាទីខេត្តតាកែវ ដោយមានការឧបត្ថម្ភពីអង្គការដៃគូផ្តល់ក្តីមេត្តា(Partner In Compassion)។
- ពិភាក្សាជាមួយដៃគូពាក់ព័ន្ធ PC CRS និងHP+ដើម្បីពិនិត្យលទ្ធភាពចលនាធនធានឧបត្ថម្ភសិក្ខាសាលាការដាក់បញ្ចូលការងារឆ្លើយតប នឹងមេរោគអេដស៍នៅក្នុងខេត្តកំពង់ស្ពឺ(គ្រប់ឃុំទាំងអស់)។
- ផ្តល់យោបល់លើTerms of Reference for Consultant ‘Development of Operational Guidelines for HIV Integration in Commune Investment Plan and Commune Development Planដែលរៀបចំដោយ UNAIDS។

ឯកឧត្តម ជា ផលា

- សកម្មភាពលើកគម្រោងមូលនិធិសកល HIV FRA (Fund Raising Application)

ក- តាមដានការលើកសំណើ HIV FRA ទៅ GFATM HQ

- Submission of HIV FRA on 31 May 2020
- Additional document on Performance Framework
- តាមដានមតិដែលលើកឡើងក្នុងកិច្ចប្រជុំ CCC លើភាពមិនចាំបាច់នៃការជ្រើសរើស និងការវាយតម្លៃ Sub Implementers។

ឯកឧត្តម ជា ផល

៣- សកម្មភាពពង្រឹងបណ្តាញក្រុមប្រជាជនគន្លឹះឆ្លើយតបនឹងមេរោគអេដស៍

(FONPAM/ DFONPAM)

- ចុះបេសកកម្មខេត្តចូលរួម “ វគ្គបណ្តុះបណ្តាលការពង្រឹងភាពដឹកនាំនិងទំនាក់ ទំនងជាតំណាង វេទិកាសហគមន៍ “(FONPAM) ដែលរៀបចំដោយ HACC នៅខេត្តបាត់ដំបង និងដោយមានការ ចូលរួមរបស់តំណាង UNAIDS ផងដែរ។
- ផ្តល់បទបង្ហាញស្តីអំពីទស្សនវិស័យ Community System Strengthening for HIV and AIDS Response ជូនដល់កិច្ចប្រជុំបណ្តាញ FONPAM/ DFONPAM (៥៣នាក់)ដែលរៀបចំ ដោយ HACC ក្នុងគម្រោងមូលនិធិសកល នៅសណ្ឋាគារភ្នំពេញ។

ឯកឧត្តម ជា ផល

៤- សកម្មភាពដឹកនាំគម្រោង NAA SSI HIV Grant 2018-2020

- សម្របសម្រួលការអនុវត្តគម្រោង បេសកកម្មទៅខេត្តនៃនាយកដ្ឋានទាំង៣ និងចុះហត្ថលេខាលើឯកសាររដ្ឋបាលនិងហិរញ្ញវត្ថុ។
- រៀបចំពង្រាង Agenda កិច្ចប្រជុំ GMC។

៥- សកម្មភាព ជាក់ឧទាហរណ៍ សជណ ២១៣

- ចូលរួមជាមួយ ឯកឧត្តម **រស់សីលវ៉ាត់** ទទួលមតិណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ អំពីការធ្វើវិមជ្ឈការឆ្លើយតបនឹងមេរោគអេដស៍នៅថ្នាក់ខេត្ត ដោយផ្តើមចេញពីខេត្តកំពង់ស្ពឺ។

ឯកឧត្តម ទា ជលា

៥- សកម្មភាព ទាក់ទងនឹង សជណ ២១៣ (ត)

- ពិភាក្សាអំពីការរៀបចំ Concept Note(ដោយមាន Costing) សម្រាប់ការធ្វើវិមជ្ឈការការអនុវត្តន៍ សជណ ២១៣ ដើម្បីឆ្លើយតបនឹងមេរោគអេដស៍នៅខេត្ត កំពង់ស្ពឺ។
- គោលនយោបាយទី៦នៃ សជណ២១៣ ចូលរួមនៅក្នុង Zoom Interview របស់លោកស្រី Rashmi Sharma ទីប្រឹក្សានៃអង្គការ HP+។

៦- សកម្មភាព ទាក់ទងនឹង Development Partners

ក- គម្រោងសកម្មភាពប្រចាំឆ្នាំរបស់អង្គការ Epic (Epidemic Control) សម្រាប់ឆ្នាំ២០២១ របស់ USAID (បន្ទាប់ពីការបញ្ចប់គម្រោង Linkages)

ឯកឧត្តម ឌា ផលា

៦- សហគ្មនាព ដាក់ឧបត្ថម្ភ Development Partners(ឥ)

- ចូលរួមប្រជុំជា Linkages/ FHI 360 Team, HACC, HQHA, HP+ , NAA លើចំណុចទាំង៥ 1) Policy & Public health system support, 2) Client-Centered services: Community Based Treatment Support ,and Stigma and Discrimination, 3) Prevention, Case finding, and Policy health system support, 4) Community Led monitoring and 5) Social Enterprise.
- បន្ទាប់ពីកិច្ចប្រជុំជាមួយ អគ្គលាខាធិការ នឹងចាត់មន្ត្រី អ.ជ.ប.ជ.អ ចូលរួមក្នុងក្រុមបច្ចេកទេសនានា 1) SI WG(NCHADS), 2) Care and Treatment WG(NCHADS) 3) HTSWG (NCHADS), 4) CoPCT WG (NCHADS), 5)GBV WG(NAA and NCHADS) and 6) CSO (Social Enterprise) ។

ឯកឧត្តម ង៉ា ផលា

៦- សកម្មភាព ដាក់ឧបនីធ Development Partners(ឥ)

ខ- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល GBV ដែលរៀបចំដោយ Linkages/ FHI (Robyn Dayton ពី USA)តាមរយៈ Zoom ជាមួយមន្ត្រីនៃកម្មវិធីនានាដែលពាក់ព័ន្ធនឹងការងារយេនឌ័រ។

គ- គម្រោង LHSS (Local Health System Sustainability) របស់ USAID

- ចូលរួមជាមួយ ឯកឧត្តម **រស់សីលង៉ាត់** ពិភាក្សាជាមួយមន្ត្រី HP+ស្តីអំពីការបន្តគម្រោង LHSS បន្ទាប់ពីគម្រោង HP+ បញ្ចប់នៅខែកញ្ញា២០២០។
- ចូលរួមជាមួយឯកឧត្តមរស់សីលង៉ាត់ពិភាក្សាជាមួយមន្ត្រី USAID និងមន្ត្រី ដែលចូលរួម Virtual Meeting ពីUSA លើ២ចំណុច។
  - ✓HIV Budgeting and Decentralization/ Deconcentration
  - ✓Monitoring the implementation of SCN 213

ឯកឧត្តម ង៉ា ផលា

ខ- សកម្មភាព ដាក់ឧបត្ថម្ភ Development Partners(ឥ)

ឃ- សកម្មភាពតាមដានការអនុវត្តន៍ទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍
(Fast Track City / UNAIDS)

- ដឹកនាំមន្ត្រី អ.ជ.ប.ជ.អ ទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការខេត្តបាត់ដំបងដែលដឹកនាំដោយលោកជំទាវអភិបាលរងខេត្ត ដើម្បីស្វែងយល់អំពីលទ្ធភាពនៃការរៀបចំផែនការទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ដោយមានការចូលរួមពីតំណាងអង្គការ HACC Buddhism for health និងUNAIDS ព្រមតំណាងមន្ទីរពាក់ព័ន្ធតំណាងសាលាខេត្តនិងតំណាងក្រុមប្រឹក្សាសង្កាត់៤នៃក្រុងបាត់ដំបងផងដែរ។
- ពិភាក្សាជាមួយដៃគូពាក់ព័ន្ធ ដូចជា UNAIDS Linkages MHC RHAC CRS...ដើម្បីពិភាក្សាលើផែនការទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍នៅខេត្តហត្ថលេខីទាំង៤(BBG BMC, SRP and PNP) ។

ឯកឧត្តម ជា ផលា

៧- សកម្មភាពផ្សេងៗ

ក- ចូលរួមក្នុងផ្តល់យោបល់លើ Monkey survey Impact of COVID 19 on HIV program / with support of UNAIDS ។

ខ- តាមដានករណីអ្នកផ្ទុកមេរោគអេដស៍នៅឃុំឆ្នាល់មាន់(ទើបរៀបការ)និងករណីយុវជន MSMឆ្លងអេដស៍ថ្មីនៅស្រុកមោងឬស្សីខេត្តបាត់ដំបង។

គ- ចុះពិនិត្យការងារបង្ការ ការចំលងមេរោគអេដស៍របស់អង្គការ RHAC នៅទីរួមខេត្តបាត់ដំបង។

ឃ- បង្រៀនប្រធានមណ្ឌលសុខភាពអំពីការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំដែលមកពី ខេត្ត/ក្រុងចំនួន ៦ គឺភ្នំពេញ តាំងឃ្មុំ ក្រចេះ ស្ទឹងត្រែង ព្រៃវែងនិង កំពង់ចាម ដែលរៀបចំដោយ NIPH។

ឃ- ជាមួយឯកឧត្តម **រស់សីលវ៉ាត់** ស្នើសុំអនុសាសន៍ពីឯកឧត្តមទេសរដ្ឋមន្ត្រីប្រធាន អ.ជ.ប.ជ.អ លើ១) Public Investment Plan ២)វីដែអូ ស្តីពីប្រជាជនគន្លឹះដែលផលិត ដោយLinkages/ FHI ៣)ការធ្វើវិមជ្ឈការការអនុវត្តន៍ SCN 213 ដើម្បីឆ្លើយតបនឹងមេរោគអេដស៍នៅខេត្តកំពង់ស្ពឺ។

លោកជំទាវ ស៊ឹម ខេងខាំ

- បានមើល និងតាមដានជារៀងរាល់ថ្ងៃ ស្តីពីសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ដែលបានធ្វើរបាយការណ៍តាមរយៈប្រព័ន្ធ Telegrame។
- ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែមិថុនា ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានអានរបាយការណ៍របស់ឯកឧត្តមអនុប្រធានដែលបានចូលរួមប្រជុំ និងទៅបំពេញបេសកម្មនៅតាមបណ្តាខេត្តនានាស្តីពី សកម្មភាពការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍។
- បានចូលក្រាបបង្គំគាល់ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្តែ ក្នុងឱកាសព្រះរាជពិធីចម្រើនព្រះជន្ម និងទូលថ្វាយរបាយការណ៍ស្តីពីវឌ្ឍនភាពរបស់ក.ជ.ក.ស។
- បានចាត់តាំងសមាជិកក្រុមការងារយេនឌ័រចំនួន៣រូប ដើម្បីចូលរួមបំពេញសំណួរក្នុងកម្មវិធីអង្កេតតាមប្រព័ន្ធOnline សម្រាប់ ការចាត់ចែងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការបញ្ចូលយេនឌ័ររបស់អាស៊ាន របស់ក្រសួងកិច្ចការនារី។

ឯកឧត្តម ស៊ឹម គឹមសៃន

- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ខែមេសា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន។
- បានពិនិត្យទៅលើឯកសារសេចក្តីព្រាង "ពាក្យបំព្រួញទាក់ទងនឹងការងារមេរោគអេដស៍ និងជំងឺអេដស៍" ដែលរៀបចំដោយអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួមកិច្ចប្រជុំប្រចាំខែ តាមរយៈប្រព័ន្ធ Blue Jeans សម្រាប់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែឧសភា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន។

ឯកឧត្តម ស៊ឹម គឹមសៃន

- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានពិនិត្យទៅលើឯកសារសេចក្តីព្រាង "គោលការណ៍ណែនាំស្តីពីការបង្ការជាសកល" ដែលរៀបចំដោយអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួមកិច្ចប្រជុំប្រចាំខែ តាមរយៈប្រព័ន្ធ Blue Jeans សម្រាប់កិច្ចថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន។

ឯកឧត្តម ស៊ឹម គឹមសែន

- បានពិនិត្យព័ត៌មានស្តីពី "យុទ្ធសាស្ត្របីសូន្យ" សម្រាប់គេហទំព័រអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដែលរៀបចំដោយឯកឧត្តមទទួលបន្ទុក។
- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ ខែមិថុនា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន។
- បានពិនិត្យលើ "គំរូអន្តរាគមន៍ឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍ និងផែនការវិនិយោគឃុំ-សង្កាត់"
- បានពិនិត្យទៅលើរបាយការណ៍កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែឧសភាក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តម ស៊ឹម គឹមសែន

- បានពិនិត្យទៅលើសៀវភៅក្រហម "សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គម" របស់ក្រសួងមហាផ្ទៃ។
- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៣ ខែមិថុនា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន។
- បានចូលរួមជាគណអធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយពីដំណើរការនៃការអនុវត្ត ការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងកំលុងពេលកូវីដ១៩។
- ចូលរួមរៀបចំវគ្គហ្វឹកហ្វឺន

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមបន្តការងារនានាដែលចាត់តាំងដោយឯកឧត្តមប្រធាន
- ត្រៀមបន្តតាមដានការអនុវត្តផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០១៩ របស់ក្រសួងធម្មការ និងសាសនា
- ត្រៀមបន្តតាមដានការអនុវត្តផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០១៩ របស់ក្រសួងបរិដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ក្រសួងយុត្តិធម្ម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ឯកឧត្តម តែង គន្ធី

- ចូលរួមកិច្ចប្រជុំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តាមរយៈវីដេអូអនឡាញ។
- ជួបពិភាក្សាជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តប៉ៃលិន ។
- ជួបពិភាក្សាជាមួយគណៈកម្មធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រះវិហារ។
- ពិភាក្សាការងារជាមួយអង្គការ MHC លើការងារបុរសរួមភេទជាមួយបុរស។

ឯកឧត្តម រស់ សីលវ៉ាត់

- ចូលរួមរៀបចំវគ្គហ្វឹកហ្វឺនមន្ត្រីបច្ចេកទេស អ.ជ.ប.ជ.អ. ដោយឆ្លុះបញ្ចាំងនូវការធ្វើអោយប្រសើរឡើងនូវ soft skill សម្រាប់ប្រើប្រាស់ក្នុងការសម្របសម្រួលការដាក់បញ្ចូលកញ្ចប់សកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ក្នុងផែនការអភិវឌ្ឍនិងផែនការវិនិយោគឃុំ ដែលនឹងចាប់ផ្តើមនៅស្រុកបសេដ្ឋ។
- ចូលរួមប្រជុំថ្នាក់ឧត្តមមន្ត្រីប្រទេសមហាអនុតំបន់ទន្លេមេគង្គតាមវីដេអូ ស្តីពីការរៀបចំខ្លួនឆ្ពោះទៅរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចនៃប្រទេសមហាអនុតំបន់ទន្លេមេគង្គ នៅចុងឆ្នាំនេះ និងកិច្ចប្រជុំកំពូលនៃប្រទេសមហាអនុតំបន់ទន្លេមេគង្គ ត្រីមាសទី១ឆ្នាំ២០២១
- ជួបពិភាក្សាការងារជាមួយមន្ត្រីអេចកីភ្លើស និងឯ.ឧ. អនុប្រធាន**ង៉ា ផល** ស្តីពីលទ្ធភាពមានគម្រោងចីរភាពនៃប្រព័ន្ធសុខាភិបាលមូលដ្ឋាន ក្រោមជំនួយឃ្លូអេសអេអាយឌី ដើម្បីត្រៀមខ្លួនផ្សារភ្ជាប់ការងារថ្មីនេះទៅនឹងការងារដែលបានចាប់ផ្តើមក្រោមការគាំទ្ររបស់អង្គការអេចកីភ្លើស។ បន្ទាប់មកបានចូលជម្រាបជូនឯកឧត្តមប្រធាននូវព័ត៌មាននេះ។

ឯកឧត្តម រស់ សីលវ៉ាត់

- ធ្វើការជាមួយយឯ.ឧ. អនុប្រធាន **ទា ផលា** និងមន្ត្រីជំនួយការបច្ចេកទេសជាន់ខ្ពស់របស់គម្រោងមូលនិធិសាកល ដើម្បីបង្កើតនូវ ទម្រង់សម្រង់បញ្ហា និងកញ្ចប់សកម្មភាពឆ្លើយតបនឹងបញ្ហា (Template) ពាក់ព័ន្ធការបង្ការ ថែទាំ ព្យាបាល និងគាំទ្រសង្គម សម្រាប់ជំងឺអេដស៍ សម្រាប់គាំទ្រការពិភាក្សាជាក្រុមក្នុងសិក្ខាសាលាអភិវឌ្ឍន៍ផែនការងារអេដស៍ឃុំសង្កាត់។
- ជួបពិភាក្សាការងារជាមួយមន្ត្រីអេចកីភ្លើស និងឯ.ឧ. អនុប្រធាន **ទា ផលា** ស្តីពីការត្រៀមប្រជុំតាមវីដេអូជាមួយម្ចាស់គម្រោង ក្នុងការពង្រឹងប្រព័ន្ធសុខាភិបាលមូលដ្ឋាន និងមន្ត្រីយូអេសអេអាយឌី ដើម្បីត្រៀមតម្រង់ទិសការងារថ្មីនេះអោយបន្តនិរន្តរភាព ដែលបានចាប់ផ្តើមក្រោមការគាំទ្ររបស់អង្គការអេចកីភ្លើស រហូតសម្រេចបាននូវការអនុវត្តពេញលេញនូវវិធានការទាំងឡាយនៃ ស.ជ.ណ.២១៣។
- ចូលរួមជាមួយឯ.ឧ. អនុប្រធានទា ផលា ប្រជុំតាមវីដេអូជាមួយម្ចាស់គម្រោងពង្រឹងប្រព័ន្ធសុខាភិបាលមូលដ្ឋាន និងមន្ត្រីយូអេសអេអាយឌី ស្តីអំពីការតម្រង់ទិសការងារថ្មីនេះអោយបន្តនិរន្តរភាពការងារដែលបានចាប់ផ្តើមក្រោមការគាំទ្ររបស់អង្គការអេចកីភ្លើស ដើម្បីគាំទ្រការអនុវត្តវិធានការទាំងឡាយនៃ ស.ជ.ណ.២១៣ អោយបានសម្រេច។

ឯកឧត្តម រស់ សីលវ៉ាត់

- ចូលរួមរៀបចំសិក្ខាសាលានៅស្រុកបាទី ខេត្តតាកែវ ក្នុងការបង្កើតផែនការឆ្លើយតបអាជ្ញាធរបស់ឃុំចំនួន ៥ សម្រាប់យកទៅដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍនិងផែនការវិនិយោគឃុំ ដោយមានការចូលរួមពីមន្ត្រីអាជ្ញាធរខេត្ត អភិបាលរងស្រុក ប្រធានស្រុកប្រតិបត្តិ មន្ត្រីមណ្ឌលសុខភាព ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ។
- ជាមួយ ឯ.ឧ. **ឆា ផលា** ចូលជម្រាបជូនឯ.ឧ. ប្រធាននូវលទ្ធផលនៃកិច្ចប្រជុំតាមវីដេអូលើគម្រោងពង្រឹងប្រព័ន្ធសុខភិបាលមូលដ្ឋាន និងលទ្ធផលនៃសិក្ខាសាលាសម្រាក់ការបញ្ជ្រៀបអាជ្ញាធរចូលក្នុងផែនការអភិវឌ្ឍនិងផែនការវិនិយោគឃុំសង្កាត់។
- ដោយអនុវត្តនូវទិសដៅរបស់ឯ.ឧ. ទេសរដ្ឋមន្ត្រីប្រធាន ធ្វើការងារជាមួយឯ.ឧ. អនុប្រធាន ទា ផលា និងមន្ត្រីអគ្គលេខាធិការដ្ឋាន ជំនួយការបច្ចេកទេសអង្គការអេចកឺក្លើស និងជំនួយការបច្ចេកទេសគម្រោងមូលនិធិសាកល រៀបចំ concept note ជម្រុញការធ្វើវិមជ្ឈការការអនុវត្តស.ជ.ណ. ២១៣ នៅខេត្តកំពង់ស្ពឺ។
- ចូលរួមប្រជុំអន្តរក្រសួង រៀបចំដោយក្រសួងផែនការ ពិនិត្យមើលទិន្នន័យស្តីកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ដែលបានដាក់បញ្ចូលដោយក្រសួងអង្គភាពទាំងឡាយ។

ឯកឧត្តម រស់ សីលវ៉ាត់

- ពិភាក្សាជាមួយឯ.ឧ. ប្រធាននិងឯ.ឧ. អនុប្រធាន **ឌា ផណា** ស្តីពី ១) ការរាយការណ៍តួលេខកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយនឹងសម្របសម្រួលជាមួយក្រសួងសុខាភិបាលថាទុកអោយ អ.ជ.ប.ជ.អ. ជាអ្នករាយការណ៍។ ២) ពិនិត្យសំនើរបស់ដៃគូអភិវឌ្ឍក្នុងការផ្សព្វផ្សាយវីដេអូឃ្លីប អំពីស្ថានភាពរើសអើងលើក្រុមប្រជាជនគន្លឹះជាសាធារណៈនៅលើវេបសាយ ដោយសម្រេចថានឹងសម្របសម្រួលអោយទុកឃ្លីបនោះប្រើតែក្នុងវេទិកាហ្វឹកហ្វឺនស្តីពីការឆ្លើយតបអេដស៍ និងការបង្កើតបរិយាកាសអំណោយផលដែលយើងមានឱកាសពន្យល់សិក្ខាកាម ហើយជៀសវាងដាក់ផ្សាយជាសាធារណៈដែលអាចបង្កប្រតិកម្មត្រលប់មិនគាប់ប្រសើរពីក្រុមអ្នករងការរិះគន់ហើយដែលកំពុងស្ថិតក្នុងសមត្ថកិច្ចលែងសហការ។
- ចូលរួមប្រជុំស្តាប់ការផ្សព្វផ្សាយអំពីអនុក្រិត១៩៣ ស្តីពីវិមជ្ឈការវិស័យសុខាភិបាល នៅក្រសួងសុខាភិបាល។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ចូលរួមរៀបចំតាមដានការអនុវត្តការងារនៃកិច្ចប្រជុំអន្តរក្រសួងស្តីពីការអនុវត្ត សជណ ២១៣។
- ចូលរួមរៀបចំការងារត្រៀមបញ្ជ្រៀបការអនុវត្តសជណ២១៣ ទៅខេត្តកំពង់ស្ពឺ។
- ត្រៀមរៀបចំការបញ្ជ្រៀបអេដស៍ចូលក្នុងផែនការសកម្មភាពឃុំឆ្នាំ២០២១នៅស្រុកបសេដ្ឋ។
- ការងារផ្សេងៗដែលយោលតាមសភាពការណ៍វិត្តន៍ចាំបាច់ និងយោលតាមការចាត់តាំងរបស់ឯ.ឧ. ប្រធាន។
- បន្តតាមដានស្ថានភាពមេរោគកូវីត១៩ ដើម្បីទប់ស្កាត់រលកទី២

ឯកឧត្តម ជា ពៅ

- ប្រជុំដើម្បីពិនិត្យទស្សនទាន ស្តីពីការដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ទៅក្នុងផែនការអភិវឌ្ឍ ឃុំ សង្កាត់ នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។
- បន្តតាមដានស្ថានភាពមេរោគកូវីត១៩ ដើម្បីទប់ស្កាត់រលកទី២
- ធ្វើការនៅ NAA
- បានទំនាក់ទំនងទៅ PAS នៅកំពង់ចាម ករណីអ្នកជំងឺអេដស៍១គ្រួសារ ដែលបានផុសតាមរយៈFB និងបានប្រាប់គាត់ អោយជួយពិនិត្យអោយបានលឿន ដើម្បីកុំអោយពួកឆ្លៀតឱកាស រាយមកលើរាជរដ្ឋាភិបាល។
- បន្តតាមដាន និងស្រាវជ្រាវឯកសារសម្រាប់ទប់ស្កាត់ការឆ្លង និងចម្លងមេរោគកូរ៉ូណា ១៩ ដើម្បីផុសក្នុងហ្វេសបុក អ.ជ.ប.ជ.អ។
- បានពិនិត្យគោលការណ៍ណែនាំ ស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកល។
- បានផុសក្នុងហ្វេសបុកផែកសរុបចំនួន ១០ដង ក្នុងខែមិថុនា

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- បន្តតាមដានករណី Covid-19 ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺនេះ
- ត្រៀមរៀបចំសិក្ខាសាលាស្តីអំពីការដាក់បញ្ចូលការឆ្លើយតបនឹងជំងឺអេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគឃុំ នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

សំណូមពរ

- ស្នើសុំថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសទាំងអស់ ដែលបានចុះបំពេញការងារ សិក្ខាសាលា កិច្ចប្រជុំផ្សេងៗ ជួយផ្តល់អត្ថបទព័ត៌មានខ្លី ភ្ជាប់ជាមួយរូបភាព ដើម្បីយកមកផុសក្នុង Facebook Page អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តម ហោ ប៊ុនឆ្លេច

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ខែមេសា ប្រចាំខែ២០២០ របស់អគ្គលេខាធិការដ្ឋាន។
- បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តាម online ។
- បានរៀបចំស្លាយបង្ហាញស្តីពីចំណេះដឹងជាមូលដ្ឋាននៃជំងឺកូវីដ១៩ សម្រាប់មន្ត្រី និងបុគ្គលិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែឧសភា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន។
- បានពិនិត្យទៅលើឯកសារសៀវភៅក្រហម "ការអនុវត្តសកម្មភាពសេវាសង្គមឃុំ-សង្កាត់" របស់ក្រសួងមហាផ្ទៃ

ឯកឧត្តម ហោ ប៊ុនឆ្លេច

- បានចូលរួមបង្ហាញស្លាយស្តីពីចំណេះដឹងជាមូលដ្ឋាននៃជំងឺកូវីដ១៩ សម្រាប់មន្ត្រី និងបុគ្គលិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ខែឧសភាឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន។
- បានរៀបចំស្លាយបង្ហាញស្តីពីចំណេះដឹងជាមូលដ្ឋាននៃការរៀបចំគម្រោងផែនការ សម្រាប់មន្ត្រី និងបុគ្គលិកអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានពិនិត្យទស្សនទានស្តីពីការរៀបចំធ្វើសមាហរណកម្មកម្មវិធីអេដស៍ទៅក្នុងផែនការផែនការអភិវឌ្ឍថ្នាក់ឃុំ។

ឯកឧត្តម ហោ ប៊ុនឆ្លេច

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៣ខែឧសភា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន
- បានចូលរួមបង្ហាញស្តីពីចំណេះដឹងជាមូលដ្ឋាននៃការរៀបចំគម្រោងផែនការ សម្រាប់មន្ត្រី និងបុគ្គលិកអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានពិនិត្យមើលឯកសារទស្សនទាន និងការរៀបចំសកម្មភាព និងថវិកាសម្រាប់ឃុំ១៥ ឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

ឯកឧត្តម ហោ ប៊ុនឆៀង

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមចូលរួមកិច្ចប្រជុំបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រៀមចូលរួមកិច្ចប្រជុំនានាតាមការចាត់តាំងរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ត្រៀមធ្វើការងារតាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

ឯកឧត្តម ស៊ឹម គឹមសាន

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ប្រចាំ ខែឧសភា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន។
- បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែ ឧសភា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀនតាម online។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែ មិថុនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន ។
- បានពិនិត្យមើលលើព័ត៌មាន ស្តីពីការចុះស្វែងយល់អំពីស្ថានភាពនៃការងារឆ្លើយតបអេដស៍នៅតាមលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងអង្គការជាដៃគូ របស់មន្ត្រីអគ្គលេខាធិការដ្ឋាន ។

ឯកឧត្តម ស៊ឹម គឹមសាន

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ខែ មិថុនា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន ។
- បានអាន និងពិនិត្យមើលលើកំណត់ហេតុកិច្ចប្រជុំថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែឧសភា ឆ្នាំ ២០២០ ។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៣ខែ មិថុនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន ។
- បានអាន និងពិនិត្យមើលកំណត់ហេតុស្តីពីការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមចូលរួមកិច្ចប្រជុំបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រៀមចូលរួមកិច្ចប្រជុំនានាតាមការចាត់តាំងរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ត្រៀមធ្វើការងារតាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

២. សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន



ឯកឧត្តម អគ្គលេខាធិការ

- ព្រឹកថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០បានចូលរួមប្រជុំរួមប្រចាំខែជាមួយ ឯកឧត្តមទេសរដ្ឋមន្ត្រី តាមរយៈ online និងបានរាយការណ៍ពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងនាយកដ្ឋានទាំង៤ ។
- រសៀលថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ បានចូលរួមប្រជុំពិនិត្យពិភាក្សាការងារចុះណែនាំការធ្វើសមាហរណកម្ម កម្មវិធីអេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ឃុំទាំង១៥ ក្នុងស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ បានដឹកនាំក្រុមការងារចុះបេសកកម្មស្វែងយល់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍របស់អង្គការ PC នៅស្រុកបរសេដ្ឋខេត្តកំពង់ស្ពឺ និងស្រុកបាទី ខេត្តតាកែវ។
- ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ បានជួបពិភាក្សាការងារជាមួយ តំណាងខាងអង្គការ HP+ អំពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ដោយចីរភាព។
- នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ ដឹកនាំក្រុមមន្ត្រីអគ្គលេខាធិការដ្ឋាន ប្រជុំពិភាក្សាជាមួយតំណាងក្រសួងសុខាភិបាលដែលដឹកនាំដោយ ឯកឧត្តមអគ្គនាយកថវិកា និងហិរញ្ញវត្ថុ លើវិធានការទី៣ នៃស.ដ.ណ ២១៣

- ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ បានជួបពិភាក្សាការងារបច្ចេកទេសតាមនាយកដ្ឋាន
- ថ្ងៃទី០៨ ខែមិថុនា ដឹកនាំវគ្គបទបង្ហាញស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ ឧទ្ទេសដោយ លោក **មិន ស៊ីថា** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់។
- ថ្ងៃទី០៩ ខែមិថុនា ជួបពិភាក្សាការងារបច្ចេកទេសតាមនាយកដ្ឋាន
- ថ្ងៃទី១០-១២ ខែមិថុនា បានដឹកនាំក្រុមការងារចុះបេសកកម្មទៅខេត្តស្វាយរៀង ដើម្បីពិនិត្យ និងស្វែងយល់ពីរការងារឆ្លើយតបមេរោគអេដស៍ និងជំងឺ អេដស៍ នៅមន្ទីរសុខាភិបាលខេត្តស្វាយរៀង និងពិនិត្យមើលការផ្តល់សេវាដល់អ្នកជំងឺអេដស៍នៅមន្ទីរពេទ្យបង្អែករមាសហែក។
- ថ្ងៃទី១៥ ខែមិថុនា បានដឹកនាំប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ និងរៀបចំកញ្ចប់ថវិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ២០២១។
- ថ្ងៃទី១៦ ខែមិថុនា បានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពីបុរសរួមភេទជាមួយបុរស ឧទ្ទេសដោយ ឯកឧត្តម **តែង គន្ធី** អនុប្រធាន អ.ជ.ប.ជ.អ។

- រសៀលថ្ងៃទី១៦ ខែមិថុនា បានដឹកនាំក្រុមការងារចុះសួរសុខទុក្ខអ្នកជំងឺអេដស៍ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម។
- ថ្ងៃទី១៧ ខែមិថុនា បានជួបពិភាក្សាការងារជាមួយ តំណាងខាងអង្គការ HP+។
- ថ្ងៃទី១៧ មិថុនា ចូលរួមបើកឯកសារដេញថ្លៃស្តីអំពីការផ្គត់ផ្គង់ ការបោះពុម្ពសៀវភៅអំពីវិស័យអេដស៍ ជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០២០។
- រសៀលថ្ងៃទី១៧ ខែមិថុនា បានប្រជុំពិភាក្សាការងារជាមួយប្រធានអង្គការ CRS។
- ថ្ងៃទី២១-២៤ ខែមិថុនា បានដឹកនាំក្រុមការងារចុះបេសកកម្មទៅខេត្ត បាត់ដំបង ដើម្បីពិនិត្យ និងស្វែងយល់ពីរការងារឆ្លើយតបមេរោគអេដស៍ និងជំងឺ អេដស៍ នៅមន្ទីរសុខាភិបាលខេត្តបាត់ដំបង។
- ថ្ងៃទី២៤ ខែមិថុនា ដឹកនាំកិច្ចប្រជុំរៀបចំថវិកាឆ្នាំ២០២១
- ព្រឹកថ្ងៃទី២៥ ខែមិថុនា កិច្ចប្រជុំជាមួយអង្គការ FHI360 ស្តីពី CamBlitz និង NCHADS Social Media Accomplishments

- ព្រឹកថ្ងៃទី២៥ ខែមិថុនា កិច្ចប្រជុំបើកឯកសារដេញថ្លៃប្រៃវ៉ែនន្ទន:
- ថ្ងៃទី២៦ ខែមិថុនា អធិបតីក្នុងពិធីប្រកាសកិច្ចសហប្រតិបត្តិការរវាង អង្គការមូលនិធិថែទាំសុខភាពអ្នកជម្ងឺអេដស៍ និងមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ លើការគាំទ្រសេវាការថែទាំការព្យាបាលដោយប្រើឱសថប្រឆាំងមេរោគអេដស៍នៅមន្ទីរពេទ្យបង្អែកមេមត់
- ព្រឹកថ្ងៃទី២៩ ខែមិថុនា បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៥ លើប្រធានបទ ១. បច្ចុប្បន្នភាពនៃអន្តរាគមន៍បង្ការមេរោគអេដស៍ និងជំងឺអេដស៍ លើក្រុមប្រឈមមុខ ភាពជោគជ័យ ការប្រឈម មេរៀនបទពិសោធន៍ និងទិសដៅរបស់អង្គការ KHANA បង្ហាញដោយលោក **ជួប សុខចំរើន** ប្រធាន KHANA ២. ការចូលរួមរបស់សហគមន៍ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ បង្ហាញដោយ ឯកឧត្តមវេជ្ជ. **ទា ផល្លា** អនុប្រធាន អ.ជ.ប.ជ.អ។
- រសៀលថ្ងៃទី២៩ ខែមិថុនា កិច្ចប្រជុំស្តីពិភាក្សាការងារស្តីពីកម្មវិធី ទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ Fast Tract Cities ជាមួយ ឯកឧត្តម **ទា ផល្លា** អនុប្រធាន អ.ជ.ប.ជ.អ

- ព្រឹកថ្ងៃទី៣០ ខែមិថុនា ចូលរួមកិច្ចប្រជុំប្រចាំខែ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ
- ពិនិត្យ ផ្តល់យោបល់លើការងារបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុប្រចាំថ្ងៃ ជូនឯកឧត្តមទេសរដ្ឋមន្ត្រី។

ឆាយកដ្ឋាន ជ.ត.ទ.ស

- នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ បានចូលរួមក្នុងកិច្ចប្រជុំរួមប្រចាំខែ ក្រោមការដឹកនាំរបស់ឯកឧត្តមអគ្គលេខាធិការនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- នៅរសៀលថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យទស្សនទាន ស្តីពីការដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ទៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួម និងធ្វើកំណត់ហេតុក្នុងកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ ក្រោមការដឹកនាំរបស់ ឯកឧត្តមអគ្គលេខាធិការនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២០ បានចុះសិក្សាស្វែងយល់ពីការធ្វើសមាហរណកម្មការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ចូលក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ នៅឃុំភារីមានជ័យ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ និងបន្តស្វែងយល់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍របស់អង្គការដៃគូមេត្តា(Partner in Compassion, PC) នៅស្រុកបាទី ខេត្តតាកែវ។

- នៅរសៀលថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ បានចូលរួមប្រជុំស្តីពីការពន្លឿនការរៀបចំកែសម្រួលវិធានការ និងនីតិវិធីក្នុងការផ្តល់និងអនុវត្តថវិកានៅស្រុកប្រតិបត្តិមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព សម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅក្រសួងសុខាភិបាល។
- បានរៀបចំសេចក្តីព្រាងលិខិត អំពីសំណើសុំផ្តល់របាយការណ៍សកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំឆមាសទី១ ឆ្នាំ២០២០ ដើម្បីបូកសរុប។
- នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលតម្រង់ទិស ស្តីពីសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គម របស់ក្រសួងមហាផ្ទៃ (សៀវភៅក្រហម) ដោយ លោក **មិន ស៊ីថា** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានធ្វើការបែងចែកសៀវភៅផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (NSP V) ទៅកាន់ខុទ្ទកាល័យដើម្បីចែកជូនថ្នាក់ដឹកនាំបានរួចរាល់។
- នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីក្រុមបុរសរួមភេទជាមួយបុរស ដោយមាន ឯកឧត្តមវេជ្ជ. **តែង គន្ធី** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាវាគ្មិន ។

- នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ បានចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេសដើម្បីពិភាក្សាលើសេចក្តីព្រាង របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក) ២០១៦-២០៣០ រៀបចំដោយក្រសួងផែនការ។
- នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ បានចុះបេសកកម្មស្វែងយល់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តបាត់ដំបង មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង មន្ទីរពេទ្យបង្អែករកា និងការពិនិត្យផ្ទៀងផ្ទាត់បញ្ជីអ្នកផ្ទុកជំងឺអេដស៍ដោយអ្នកស្ម័គ្រចិត្ត និងអង្គការសង្គមស៊ីវិលដែលធ្វើការងារអេដស៍។
- នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ បានចូលរួមកិច្ចប្រជុំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងផែនការថវិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២១ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានរៀបចំលិខិតអញ្ជើញមន្ត្រីតាមបណ្តាលក្រសួងដែលពាក់ព័ន្ធ ដើម្បីចូលរួមកិច្ចប្រជុំសម្របសម្រួលស្តីពីការបង្កបរិយាកាស គាំទ្រ ច្បាប់ និងគោលនយោបាយ ក្នុងការគាំទ្រឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- រៀបចំលិខិតណែនាំដល់គណៈកម្មាធិការអេដស៍ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្នុងការរៀបចំផែនការសកម្មភាពថវិកាការងារអេដស៍ ដាក់ក្នុងផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំ និងផែនការថវិកាឆ្នាំ២០២១។

- បានបញ្ចប់ការបកប្រែជាភាសាខ្មែរនូវផែនការយុទ្ធសាស្ត្រជាតិជាពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ ឆ្នាំ២០១៩-២០២៣ និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ សម្រេច។
- បានរៀបចំឯកសារការផ្លាស់ប្តូរប្រកបដោយចីរភាពក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- បានរៀបចំ និងពិនិត្យផែនការសកម្មភាព របស់អគ្គលេខាធិការដ្ឋាន និងរបស់នាយកដ្ឋាន PMER នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០២០។
- នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ បានចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ដែលរៀបចំដោយក្រសួងផែនការ។ ក្នុងនោះយើងពិនិត្យឃើញតួលេខត្រួតគ្នាជាមួយក្រសួងសុខាភិបាល បានពិភាក្សាគ្នារកដំណោះស្រាយ។ តាមការណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ឱ្យ អ.ជ.ប.ជ.អ ជាអ្នករាយការណ៍រួម រាល់គម្រោងកម្មវិធីឆ្លើយតបមេរោគអេដស៍ នៅកម្ពុជា។

ផែនការខែបន្ទាប់

- បន្តការងារពិនិត្យឯកសារផែនការយុទ្ធសាស្ត្រជាតិជាពហុវិស័យឆ្លើយតបមេរោគអេដស៍ និងដំងឺអេដស៍ លើកទី៥ ឆ្នាំ២០១៩-២០២៣ ភាសាខ្មែរសម្រាប់ការបោះពុម្ព។
- បន្តរៀបចំ និងពិនិត្យផែនការសកម្មភាព របស់អគ្គលេខាធិការដ្ឋាន និងរបស់នាយកដ្ឋាន PMER នៃអាជ្ញាធរជាតិប្រយុទ្ធនឹងដំងឺអេដស៍ សម្រាប់ឆ្នាំ២០២១។
- បន្តតាមដានលិខិត អំពីសំណើសុំផ្តល់របាយការណ៍សកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងដំងឺអេដស៍ ប្រចាំឆមាសទី១ ឆ្នាំ២០២០ ដើម្បីបូកសរុប។
- បន្តការងារសម្របសម្រួលជាមួយ NCHADS និង MOH ដើម្បីកែសម្រួលកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល និងផ្ញើដូនក្រសួងផែនការ។

នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ

- បានសម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំប្រចាំខែអគ្គលេខាធិការដ្ឋាន នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ពីម៉ោង ០៩:០០ ដល់ម៉ោង១១:០០ព្រឹក។ កិច្ចប្រជុំបានស្តាប់ និងពិភាក្សាដោះស្រាយលើ ៖ ១) របាយការណ៍នាយកដ្ឋានទាំង៤ និង ២) កិច្ចការផ្សេងៗ។ ក្នុងនោះក្រៅពីការរាយការណ៍របស់នាយកដ្ឋានទាំង៤ ក៏មានការពិភាក្សាអំពីការរៀបចំជនបង្គោលខាងទំនាក់ទំនងជាមួយអង្គការ ដើម្បីសម្របសម្រួលការងារផងដែរ។ កិច្ចការដែលឯកឧត្តមអគ្គលេខាធិការណែនាំឱ្យធ្វើបន្តរួមមាន ៖ ១) ការរៀបចំការកំណត់តួនាទី និងភារកិច្ចជនបង្គោលទំនាក់ទំនង ដើម្បីដាក់ពិភាក្សាក្នុងកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ នៅថ្ងៃចន្ទសប្តាហ៍ក្រោយ ២) ការបកប្រែ និងការឈូសរំលើងការប្រែសម្រួលផែនការយុទ្ធសាស្ត្រជាតិ លើកទី៥ ស្នើបញ្ចប់នៅក្នុងសប្តាហ៍នេះ ៣) ការពង្រឹងបន្ថែមនូវឯកសារ និងលិខិតស្នាមដាក់ជូនថ្នាក់ ៤) ការពន្លឿនលើការធ្វើរបាយការណ៍ (ស្នើសុំបញ្ចប់ឱ្យបានឆាប់ យ៉ាងយូរត្រឹមតែពេលមួយសប្តាហ៍) ៥) ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអង្គការ និង៦) ការពិភាក្សាលើការរៀបចំកិច្ចប្រជុំពេញអង្គលើកទី១ ថា តើគួរធ្វើតាមវីដេអូខនហ្វឺរេន (online) ឬលើកទៅខែធ្នូ ដើម្បីបានចូលរួមជួបមុខគ្នា។

- បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលបន្តក្នុងការដាក់បញ្ចូលការឆ្លើយតបនឹងមេរោគអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០។ ចាប់ពីម៉ោង២:៣០រសៀល។ ក្នុងនោះយើងបានពិភាក្សា អំពីរបៀប និងវិធីសាស្ត្រក្នុងការបណ្តុះបណ្តាលក្រុមការងារឃុំ ដើម្បីធានាថាយើង ផ្តោតការយកចិត្តទុកដាក់លើអ្នកភូមិនៅមូលដ្ឋាន ជាពិសេសគឺអ្នកស្មគ្រចិត្តឃុំ និង អ្នកផ្ទុកមេរោគអេដស៍។
- បានបញ្ចប់ការជួយកែសម្រួលឯកសារគោលការណ៍ណែនាំស្តីពី ការបង្ការការចម្លង មេរោគអេដស៍ជាសកល និងផ្ញើជូនឯកឧត្តមអគ្គលេខាធិការ នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០។
- នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ បានសម្របសម្រួលក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំសង្កាត់ ដែលបានបោះពុម្ពផ្សាយនៅខែឧសភា ឆ្នាំ២០១៨ ដោយក្រសួងមហាផ្ទៃ ដល់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន។ លោក មិន ស៊ីថា អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុងស្រុកឃុំសង្កាត់នៃក្រសួងមហាផ្ទៃ ជាវាគ្មិន និងសម្របសម្រួលដោយបុគ្គលិកអង្គការUNICEF។

- បានចូលរួមប្រជុំពិភាក្សាលើការពន្លឿនការរៀបចំកែសម្រួលវិធាន និងនីតិវិធីក្នុងការ ផ្តល់និងអនុវត្តថវិកានៅស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពសម្រាប់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ ពីម៉ោង៣ដល់៤រសៀលនៅទីស្តីការក្រសួងសុខាភិបាល រវាងប្រតិភូអាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ដែលដឹកនាំដោយឯកឧត្តមអគ្គលេខាធិការ ជាមួយនឹងតំណាងក្រសួងសុខាភិបាលដែលដឹកនាំដោយឯកឧត្តមអគ្គនាយកថវិកា និងហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះក៏មានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអគ្គលេខាធិការរង អគ្គនាយករង ប្រធាន និងអនុប្រធាននាយកដ្ឋាននៃស្ថាប័នទាំងពីរផងដែរ។ ចំណុចដែលលើកយកមកពិភាក្សារួមមាន ៖ ១) ការគាំទ្រដល់អ្នកស្ម័គ្រចិត្តឃុំ ២) ការដឹកជញ្ជូនតេស្តឈាម ៣) ការឧបត្ថម្ភអ្នកផ្ទុកមេរោគអេដស៍ពេលមកទទួលសេវា៤) ការឧបត្ថម្ភអ្នកថែទាំអ្នកជំងឺអេដស៍ និង៥) ការប្រើប្រាស់ថវិកាសម្រាប់ទិញឱសថដែលខ្វះខាត។ ជាលទ្ធផល តំណាងក្រសួងសុខាភិបាល បានឯកភាពលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងដើម្បីសម្រេចលើ ការងារដឹកជញ្ជូនតេស្តឈាម។ ឯការឧបត្ថម្ភអ្នកជំងឺពេលមកទទួលសេវា អ្នកថែទាំ និងការប្រើប្រាស់ថវិកាដើម្បីទិញឱសថគឺមាននៅក្នុងខ្ទង់ចំណាយស្រាប់ហើយ ដែលមណ្ឌលសុខភាព ឬមន្ទីរពេទ្យជាអ្នកកំណត់អាទិភាពចាយដោយខ្លួនឯង។ ចំពោះការជួយគាំទ្រដល់អ្នកស្ម័គ្រចិត្តឃុំ ក្រសួងនឹងពិនិត្យមើលថាអាចជួយកម្រិតណា។

- បានធ្វើលិខិតឧទ្ទេសនាមជូននាយកដ្ឋានទាក់ទង និងចលនាប្រកពធនធានចូលរួមកិច្ចប្រជុំសម្របសម្រួលដើម្បីឱ្យក្រុមប្រជាជនគន្លឹះទទួលបានសេវាថែទាំសុខភាពប្រសើរជាងមុន ដែលគាំទ្រដោយមូលនិធិសកលនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង៨:៣០នាទីព្រឹក នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួមប្រជុំទទួលការណែនាំអំពី ការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល នៅគណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ នៅថ្ងៃទី១១ ខែមិថុនា គម្រប់ព្រះជន្ម៨៤យាងចូល៨៥ព្រះវស្សា។
- បានរៀបចំ និងធ្វើបទបង្ហាញអំពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងផែនការថវិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២១ ក្នុងកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍អគ្គលេខាធិការដ្ឋាននៅព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។ របៀបវារៈនៃកិច្ចប្រជុំរួមមាន ៖ ១) ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងផែនការថវិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២១ និង២) កិច្ចការផ្សេងៗ។

- បានសម្របសម្រួលក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ក្រុមបុរសរួមភេទជាមួយបុរស ដោយមានឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី ជារាគ្មិន នៅថ្ងៃអង្គារ ទី១៦ ខែមិថុនា ឆ្នាំ២០២០ ចាប់ពីម៉ោង០៩:០០ព្រឹក ដល់ថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន។
- បានប្រជុំប្រចាំសប្តាហ៍នាយកដ្ឋានចំនួន៣ដង ដើម្បីពិនិត្យមើល និងតាមដានការងារដែលបានអនុវត្ត និងដាក់ផែនការអនុវត្តបន្តក្នុងសប្តាហ៍ តាមកម្មវិធី BlueJeans នៅរសៀលថ្ងៃទី១ និង៨ ខែមិថុនា និងប្រជុំផ្ទៀល់មុខ នៅថ្ងៃទី១៧ ខែមិថុនា។ ក្នុងនោះបានពិភាក្សាអំពី ៖ ១) ការងារ និងបញ្ហាដែលត្រូវដោះស្រាយ (វឌ្ឍនភាពក្នុងការរៀបចំឯកសារទូទាត់ចំណាយដំណើរការរដ្ឋបាល និងបេសកកម្ម) ២) ការពង្រឹងការទទួលខុសត្រូវទៅតាមតួនាទី និងភារកិច្ច ជាពិសេសការិយាល័យទាំង៥ (ការចាត់ចែងមន្ត្រីដោះស្រាយការងារ) ៣) ផែនការការងារ (ការរៀបចំឯកសារឡើងទូទាត់បន្ត និងការត្រៀមរៀបចំផែនការថវិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២១) និង ៥) ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងផែនការថវិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២១ ៦) ការបើកឱ្យដំណើរការធម្មតាវិញចាប់ពីថ្ងៃទី១ ខែកក្កដា ៧) ការសិក្សាអំពីលទ្ធភាពក្នុងការរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅខែកក្កដា ៨) កិច្ចការផ្សេងៗ (ការពង្រឹងសន្តិសុខ និងអនាម័យ)។

- បានរៀបចំ និងចាត់ចែងឱ្យផ្សព្វផ្សាយលិខិតថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម គម្រប់ព្រះជន្ម៨៤យាងចូល៨៥ព្រះវស្សា ដែលត្រូវនឹងថ្ងៃទី១៨ ខែមិថុនា តាមwebsite Facebook page របស់អាជ្ញាធរ និង បណ្តាញព័ត៌មានFresh News នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០។
- បានចាត់ចែងឱ្យមន្ត្រីយកលិខិត និងកន្ត្រកផ្កាថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម គម្រប់ព្រះជន្ម៨៤យាងចូល៨៥ព្រះវស្សា (ដែលត្រូវនឹងថ្ងៃទី១៨ ខែមិថុនា) ទៅព្រះបរមរាជវាំង នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២០។
- បានចាត់ចែងឱ្យមន្ត្រីចងបជាអបអរសាទរ ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ព្រះជន្ម៨៤យាងចូល៨៥ ព្រះវស្សា សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តី ថ្លៃថ្នូរ និងសុភមង្គលនៅអគារអាជ្ញាធរ។

- បានប្រជុំជាមួយនាយកដ្ឋានបច្ចេកទេសទាំង៣ ដើម្បីពិនិត្យ និងកែសម្រួលសូចនាករ នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ និងផែនការថវិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២១ នៅរសៀលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។
- បានចូលរួមក្នុងកិច្ចប្រជុំ បើកឯកសារដេញថ្លៃផ្គត់ផ្គង់ការបោះពុម្ពសៀវភៅអំពីវិស័យ អេដស៍ជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំឆ្នាំ២០២០ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ចាប់ពីម៉ោង៩:៣០ព្រឹក។
- បានផ្ទៀងផ្ទាត់កាំប្រាក់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការដែលបានប្រកាសដំឡើងឋានន្តរស័ក្តិ និងថ្នាក់តាមវេនឆ្នាំ ២០២០ សរុបចំនួន៣០រូប ក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស នៅក្រសួងសុខាភិបាល។
- បានកែសម្រួលតារាងឋានន្តរស័ក្តិថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន ២រូបដែលដល់អាយុចូលនិវត្តន៍ក្នុងឆ្នាំ២០២១។
- បានធ្វើបច្ចុប្បន្នភាពតារាងតាមដានអាយុចូលនិវត្តន៍ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីធ្វើការពិនិត្យ និងជូនព័ត៌មានប្រចាំឆ្នាំ។

- បានរៀបចំ ១) បណ្ណស្នើសុំសម្ភារ និងបញ្ជេញសម្ភារ ២) សលាកប័ត្រឃ្លាំង និង៣) ឯកសារស្នើសុំថវិកាសម្រាប់ការចំណាយនៅដំណើរការរដ្ឋបាលសរុបចំនួន៣៩ច្បាប់។
- បានពិនិត្យនិងរៀបចំប័ណ្ណាស្នើសុំទូទាត់ថវិកាដើម្បីស្នើសុំការសម្រេចចំនួន១២ច្បាប់។
- បានទទួលឯកសារបេសកកម្មដែលត្រឡប់មកពីខេត្តវិញចំនួន២២ច្បាប់។
- បានធ្វើការទូទាត់សោហ៊ុយបេសកកម្មដែលត្រឡប់មកពីខេត្តវិញចំនួន១៤ច្បាប់។
- បានធ្វើតារាង ក ខ ទូទាត់ប្រាក់បេសកកម្ម បានចំនួន២៩ច្បាប់។
- បានឡើងតារាង ក ខ សរុបទូទាត់ប្រាក់បេសកកម្ម បានចំនួន២៩ច្បាប់។
- បានឡើងតារាងសរុបប្រាក់បេសកកម្ម សម្រាប់ត្រៀមទូទាត់ត្រង់ចំនួន២៩ច្បាប់។
- បានបញ្ចូលឯកសាររដ្ឋទេយ្យចូលតារាងទូទាត់ និងចុះលេខលើប័ណ្ណចំណាយចំនួន ៥ឯកសារ។

- បានរៀបចំឯកសារទូទាត់សិក្ខាសាលាបណ្តុះបណ្តាលស្តីពី ការដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍នៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ និងសិក្ខាសាលាបណ្តុះបណ្តាលស្តីពី អត្តសញ្ញាណកម្មគ្រួសារក្រីក្រជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រី នៃ អ.ជ.ប.ជ.អ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០។
- បានរៀបចំឯកសារស្នើសុំឥណទានថវិកាតាមកម្មវិធីជំពូក៦១ សម្រាប់ទូទាត់ថ្លៃប្រើប្រាស់ទូរស័ព្ទអចល័តរបស់ អ.ជ.ប.ជ.អ ពីខែមីនា ដល់ខែឧសភា ឆ្នាំ២០២០ ជូនទូរគមនាគមន៍កម្ពុជា។
- បានពិនិត្យលើភាពត្រឹមត្រូវ និងបញ្ចូលថវិកាដែលបានស្នើសុំចំណាយចំនួន២៤ច្បាប់ ដើម្បីតាមដានវដ្ដទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានពិនិត្យ និងតាមដានឥណទានគោលការណ៍ធានាចំណាយចំនួន៤ (ទិញអាវក្លៀង សម្ភារការិយាល័យ សម្ភារបរិក្ខារ គ្រឿងសង្ហារិម និងសម្ភារបរិក្ខាព័ត៌មានវិទ្យា)

- បានរៀបចំកាត់ថវិកាក្នុងអនុគណនីនីមួយៗ ក្នុងតារាងតាមដានឥណទានរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយយោងតាមសារាចរណែនាំលេខ០០១ និង ០០៣សហវ.អច របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយ ក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០។
- បានរៀបចំកាត់ថវិកាដែលបានចំណាយលើសាលាកប័ត្រ សម្រាប់សំណើទិញសម្ភារ បរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា សង្ហារិម សម្ភារការិយាល័យ ទិញសម្ភារ បរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា ទិញអាវក្លៀងផ្សព្វផ្សាយព័ត៌មានអំពីជំងឺអេដស៍។
- បានរៀបចំចុះប្រតិបត្តិការសំណើសុំគោលការណ៍ធានាចំណាយ ក្នុងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់សំណើទិញសម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា សង្ហារិម សម្ភារការិយាល័យ ទិញសម្ភារបរិក្ខារបច្ចេក ទេសព័ត៌មានវិទ្យា ទិញអាវក្លៀងផ្សព្វផ្សាយព័ត៌មានអំពីជំងឺអេដស៍ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២០។
- បានលុបគោលការណ៍ដែលបានស្នើសុំធានាចំណាយ នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មុនពេលចេញសារាចរ លេខ០០១ និង០០៣ ព្រម ទាំងទាញថវិកាត្រឡប់ចូលមកក្នុងកញ្ចប់ដើមវិញ។

- បានទទួលគោលការណ៍ធានាចំណាយ ប្រែងឥន្ធនៈ និងប្រែងរំអិល ឆ្នាំ២០២០។
- តាមដាន និងដោះស្រាយឯកសារស្នើសុំគោលការណ៍ធានាចំណាយ ឆ្នាំ២០២០ ចំនួន៤ ដែលកំពុងបន្តនីតិវិធីរួមមាន ៖ ១) ការទូទាត់បេសកកម្មក្នុងប្រទេស (ទូទាត់ត្រង់ និងតាមរដ្ឋទេយ្យ) ចំនួន២ឯកសារ និង២) ឯកសាររដ្ឋទេយ្យដំណើរការចាំបាច់ផ្សេងៗ ចំនួន១ឯកសារ និង៣) ការកែតម្រូវតារាងរដ្ឋទេយ្យតាមសារាចរណែនាំស្តីពីវិចារណកម្មចំណាយ ចំនួន១ឯកសារ។
- ធ្វើការជាមួយអភិបាលហិរញ្ញវត្ថុ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើការកាត់បន្ថយ ខ្ចង់ចំណាយតាមអនុគណនីដើម្បីផ្ទៀងផ្ទាត់តាមនីតិវិធីចំណាយឡើងវិញទៅតាមគោលការណ៍ណែនាំស្តីពីវិចារណកម្មចំណាយលើកទី២របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាការឆ្លើយតបនឹងការរីករាលដាលមេរោគកូវីដ១៩។
- បានប្រជុំពិភាក្សាការងារនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងផែនការថវិកាអាជ្ញាធរ ឆ្នាំ២០២១ នៅថ្ងៃទី១០ ខែមិថុនា ក្នុងនោះយើងនឹងលើកផែនការថវិកាទៅតាមសារាចរណែនាំ លេខ០៣សរណន ចុះថ្ងៃទី៩ ខែមិថុនា ឆ្នែ២០២០ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងសារាចរណែនាំ លេខ០៤សរណន ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

ផែនការសកម្មភាពខែបន្ទាប់

- តាមដានការងារប្រចាំសប្តាហ៍ និងធ្វើការប្រជុំនាយកដ្ឋាន ដើម្បីពិនិត្យមើល និងតាមដានការងារដែលបានអនុវត្ត និងដាក់ផែនការអនុវត្តបន្តក្នុងសប្តាហ៍។ ក្នុងនោះនឹងពិភាក្សាអំពី ១) ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ និងសេចក្តី ព្រាងផែនការថវិកា ឆ្នាំ២០២១អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ២) ការពន្លឿនការងារទូទាត់ថវិកា និង ៣) ការពង្រឹងសន្តិសុខ និងអនាម័យ។
- សិក្សាអំពីលទ្ធភាពក្នុងការរៀបចំកិច្ចប្រជុំពេញអង្គ ដែលគ្រោងធ្វើនៅចុងខែកក្កដា ថ្ងៃ នៅទីស្តីការគណៈរដ្ឋមន្ត្រី ឬរៀបចំតាមវីដេអូខនហ្វឺរេន។
- បន្តតាមដាន និងដោះស្រាយឯកសារស្នើសុំគោលការណ៍ជានាចំណាយ ឆ្នាំ២០២០ ចំនួន៤ដែលកំពុងបន្តនីតិវិធីរួមមាន ៖ ១) ការទូទាត់បេសកកម្មក្នុងប្រទេស (ទូទាត់ត្រង់ និងតាមរដ្ឋទេយ្យ) ចំនួន២ឯកសារ ៣) ឯកសាររដ្ឋទេយ្យដំណើរការចាំបាច់ ផ្សេងៗ ចំនួន១ឯកសារ។

- បន្តតាមដាន និងដោះស្រាយឯកសារស្នើសុំគោលការណ៍ធានាចំណាយ ឆ្នាំ២០២០ ចំនួន៤ដែលកំពុងបន្តនីតិវិធីរួមមាន ៖ ១) ការទូទាត់បេសកកម្មក្នុងប្រទេស (ទូទាត់ត្រង់ និងតាមរដ្ឋទេយ្យ) ចំនួន២ឯកសារ ៣) ឯកសាររដ្ឋទេយ្យដំណើរការចាំបាច់ ផ្សេងៗ ចំនួន១ឯកសារ។
- បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ និងសេចក្តីព្រាងផែនការថវិកា ឆ្នាំ២០២១ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- **បញ្ហាប្រឈម និង/ឬ សំណូមពរ**
- ស្នើពន្លឿនឯកសារចំណាយថវិការដ្ឋទេយ្យបុរេប្រទាន ដើម្បីធាប់បានដាក់ឡើងទូទាត់ និងស្នើសុំដកថវិកាមកប្រើប្រាស់បន្ត។
- សូមអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីមកបើកថវិកាទូទាត់បេសកកម្មក្នុងប្រទេស ដែលបានបំពេញពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣ ខែមករា ឆ្នាំ២០២០ នៅអ្នកស្រីវង្សឌី ទេពី រដ្ឋទេយ្យកររង ចាប់ពីថ្ងៃទី រសៀល ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២នេះ រហូតដល់មុនដំណាច់សប្តាហ៍ក្រោយ។

នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ

- បានប្រជុំប្រចាំខែក្នុងនាយកដ្ឋាន២លើក និងបានរៀបចំផែនការរបស់នាយកដ្ឋាន ដើម្បី លើកផែនការសកម្មភាពសម្រាប់អនុវត្តបន្ត និងពង្រឹងការៈកិច្ចទទួលខុសត្រូវ របស់ មន្ត្រីក្នុងនាយកដ្ឋាន
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសៀវភៅក្រហម ទាក់ទងនឹងការងារឃុំ សង្កាត់ បង្ហាញដោយតំណាងក្រសួងមហាផ្ទៃ និង យូនីសេហ្វ ក្រោមការដឹកនាំរបស់ ឯកឧត្តម អគ្គលេខាធិការ និងវគ្គបណ្តុះបណ្តាល ស្តីពីស្ថានភាព ក្រុមបុរសស្រឡាញ់បុរស បទបង្ហាញ ដោយ ឯកឧត្តម តែង គន្ធី អនុប្រធាន អជបជអ
- បានធ្វើការប្រមូលទិន្នន័យពីក្រុមប្រជាជនគន្លឹះ ដើម្បីបានព័ត៌មានថ្មីៗពីចំនួន KP, PLHIV, VCCT, MSM/TG, FEW
- បានប្រជុំរៀបចំផែនការនាយកដ្ឋាន សម្រាប់អនុវត្តសកម្មភាព របស់មូលនិធិសកល ត្រីមាសទី៣ឆ្នាំ២០២០ និង ផែនការថវិកាជាតិ ឆ្នាំ ២០២១ - ២០២២៖ បានពិនិត្យផែនការអាចិភាព របស់ អជបជអ និងនាយកដ្ឋាន ចូលរួមបង្កើត សូចនករបានលើកផែនការសកម្មភាពសម្រាប់គម្រោងបន្ទាប់ របស់នាយកដ្ឋាន (ត្រីមាសទី៤)

- បានចូលរួមប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ និងប្រចាំខែ ក្រោមការដឹកនាំប្រជុំ ដោយ ឯកឧត្តម ប្រធាន និង ឯកឧត្តម អគ្គលេខាធិការ។
- បានបន្តពិនិត្យ និងកែសម្រួល អោយប្រសើរឡើង ពីគោលការណ៍ណែនាំស្តីពីការការពារ មេរោគអេដស៍ ជាសកល៖បានកែរសម្រួលតាមអនុសាសន៍ណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងបានដាក់ជូនឯកឧត្តម អគ្គលេខាធិការពិនិត្យ និងផ្តល់អនុសាសន៍។
- បានបន្តរៀបចំ និងពិនិត្យឡើងវិញ លើប្លង់មេរៀន សម្រាប់ធ្វើការបណ្តុះបណ្តាលគ្រូបង្គោល ស្តីពី បរិយាកាសគាំទ្រ និងការឆ្លើយតបមេរោគអេដស៍ នឹងជំងឺអេដស៍តាមរយៈដៃគូសហគមន៍ ៖ បានពិនិត្យកែសម្រួលវិធីសាស្ត្រ និងខ្លឹមសារមេរៀនធ្វើអោយប្រសើរថែមទៀតនូវគុណភាពស្លាយបង្ហាញពិនិត្យពេលម៉ោងអោយបានសមស្របជ្រើសរើសវីដេអូនិងខ្លឹមសារវីដេអូឃ្លីបសម្រាប់អប់រំបន្ត។
- បន្តរៀបចំផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលពី EE-MCPI-DD សម្រាប់ខេត្ត ស្វាយរៀង, សៀមរាប និង ត្បូងឃ្មុំ ។

- បានបន្តរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីការបង្កបរិយា កាសអំណោយផលសម្រាប់ក្រុមប្រជាជនគន្លឹះក្នុងការឆ្លើយតបមេរោគអេដស៍នឹងជំងឺអេដស៍នៅថ្នាក់ខេត្ត និងជធានីះបានពិនិត្យលើរបាយការណ៍អនុវត្តកន្លងមកបានពិនិត្យស្ថានភាពថ្នាក់ខេត្តដែលស្នើឡើងក្នុងកិច្ចប្រជុំដើម្បីធ្វើការដោះស្រាយ។ បានលើកទិសដៅសម្រាប់អនុវត្តនៅត្រីមាសបន្ទាប់
- ចុះអភិបាលកិច្ច ការឆ្លើយតបទៅនឹងជំងឺអេដស៍ នៅថ្នាក់ ខេត្ត (កំពត)។
- បានរៀបចំរបាយការណ៍កិច្ចប្រជុំផ្សេងៗសម្រាប់អគ្គលេខាធិការដ្ឋាន ថ្នាក់ដឹកនាំ និងដៃគូពាក់ពន្ធ័។

ផែនការសកម្មភាពខែបន្ទាប់

- បន្តរៀបចំប្រជុំបច្ចេកទេស និងប្រជុំប្រចាំត្រីមាស នៃក្រុមការងារ MSM/TG និង FEW, ដើម្បីៈបានទទួលយោបល់បន្ថែមលើផែនការ សកម្មភាពរបស់ក្រុមការងារ ចែករំលែកព័ត៌មាននិងចំណេះដឹងទៅវិញទៅមកអំពីក្រុមប្រឈមមុខខ្ពស់បង្កើនកិច្ចសហការនិងបទអន្តរាគមន៍សម្រាប់ក្រុមប្រជាជនគន្លឹះ និងប្រមូលព័ត៌មាននៃការឆ្លងថ្មីៗ
- បន្តពង្រឹងមន្ត្រីក្នុងនាយកដ្ឋានក្នុងការទទួលខុសត្រូវតួនាទីការៈកិច្ច, ដើម្បីៈផ្តល់វគ្គបណ្តុះបណ្តាលកិច្ចប្រជុំអោយបានទៀងទាត់លើកទឹកចិត្ត
- បន្តរៀបចំការងារបច្ចេកទេសសំរាប់ការចុះអភិបាលការងារឆ្លើយតបមេរោគអេដស៍តាមរយៈដៃគូ សហគមន៍នៅថ្នាក់ខេត្ត, ដើម្បីៈផ្តល់ការតម្រង់ទិសនិងលើកសកម្មភាពគន្លឹះៗសំរាប់អនុវត្តការងារអេដស៍ នៅថ្នាក់ខេត្តបង្កើនកិច្ចសហការរវាងអ្នកផ្តល់សេវា និងអាជ្ញាធរដែនដីលើកទឹកចិត្តដល់ PAS/PAC, PAO ជួយជម្រុញបន្ថែមអោយបានខ្លាំងក្លាក្នុងការលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០៣០
- បន្តការងារតាមដានទិន្នន័យក្រុមប្រជាជនគន្លឹះ,ដើម្បីៈ គ្រប់គ្រងពីចំនួនក្រុមប្រឈមមុខខ្ពស់ដឹងពីអត្រាអ្នករស់នៅជាមួយមេរោគអេដស៍ដឹងពីចំនួននិងកន្លែងផ្តល់សេវា

- បន្តចុះពិនិត្យស្ថានភាព នៃការឆ្លើយតបទៅនឹងជំងឺ អេដស៍តាមរយៈដៃគូសហគមន៍ នៅថ្នាក់ខេត្តនិងឃុំ សង្កាត់ក្នុងខេត្ត (បាត់ដំបង, បន្ទាយមានជ័យ, ក្រចេះ, រតនគីរី), ដើម្បីៈផ្តល់ការតម្រង់ទិស និងលើកសកម្មភាពគន្លឹះៗ សំរាប់អនុវត្តការងារអេដស៍នៅថ្នាក់ខេត្តបង្កើនកិច្ចសហការរវាងអ្នកផ្តល់សេវានិងអាជ្ញាធរដែនដីលើកទឹកចិត្តដល់ PAS/PAC, PAO, CAC ជួយជម្រុញបន្ថែមអោយបានខ្លាំងក្លាក្នុងការលុបបំបាត់ជំងឺអេដស៍ នៅឆ្នាំ២០២៥ជម្រុញអោយប្រសើរឡើងក្នុងការអនុវត្តន៍គោលនយោបាយ ភូមិ/ឃុំ មានសុវត្ថិភាពស្តីពីជំងឺអេដស៍។
- បន្តរៀបចំនិងផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពី បរិយាកាសគាំទ្រច្បាប់ គោលនយោបាយ និងការៈកិច្ចក្នុងការគាំទ្រឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិសម្រាប់ខេត្តស្វាយរៀង, កំពង់ធំ, ព្រៃវែង រតនគីរី។
- បន្តរៀបចំកិច្ចប្រជុំប្រចាំត្រីមាសស្តីពី EE-MCPI-DD សម្រាប់ថ្នាក់ខេត្តប្រឈមមុខខ្ពស់
- បន្តកែសម្រួល អោយប្រសើរឡើង ពីគោលការណ៍ណែនាំ ស្តីពីការការពារមេរោគអេដស៍ ជាសកល

ឧបសម្ព័ន្ធ ទាក់ទង និងចលនាប្រតិភូធនធាន

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសៀវភៅណែនាំការអនុវត្តសេវាសង្គម(សៀវភៅក្រហម)
- រៀបចំឯកសារស្តីពីបទពិសោធន៍សមាហរណកម្មកម្មវិធីឆ្លើយតបមេរោគអេដស៍ក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់របស់មូលនិធិសង្គ្រោះសហគមន៍សម្រាប់ធ្វើបទបង្ហាញមន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ដំណើរការនិតិវិធីរដ្ឋបាលឯកសាររបាយការណ៍បណ្តុះបណ្តាល និងក្រុមប្រឹក្សាបច្ចេកទេសជូនថ្នាក់នាំចុះហត្ថលេខា
- រៀបចំកិច្ចប្រជុំសម្របសម្រួលស្តីពីការផ្តល់សេវាឱ្យប្រសើរជាង មុនដល់អ្នកផ្ទុកមេរោគអេដស៍នៅរាជធានីភ្នំពេញ
- សម្របសម្រួលវគ្គបណ្តុះបណ្តាលសាកល្បងស្តីពីសមាហរណកម្មកម្មវិធីឆ្លើយតបមេរោគអេដស៍ក្នុងផែនការអភិវឌ្ឍឃុំ នៅតាកែវ
- ចុះអភិបាលកិច្ចការឆ្លើយតបមេរោគអេដស៍ក្នុងឃុំ សង្កាត់ខេត្តប៉ៃលិន

- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសតាមប្រព័ន្ធBlue Jeans
- ចូលរួមប្រជុំបច្ចេកទេសពិភាក្សាពីការរៀបចំថវិកាសម្រាប់ឆ្នាំ២០២១-២០២៣
- ប្រជុំពិភាក្សាលើការកំណត់សុចនាករសកម្មភាពសម្រាប់ការកាត់បន្ថយថវិកាជាតិ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបុរសស្រឡាញ់បុរសបង្ហាញដោយ ឯកឧត្តម តែង គន្ធី អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីគម្រោងការសិក្សាពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការឆ្លើយតបមេរោគអេដស៍
- ជួបពិភាក្សាជាមួយអង្គការCRSស្តីពីGoal Vision and Mission ព្រមទាំងសកម្មភាពដែលអនុវត្តដោយអង្គការCRS
- ចូលរួមប្រជុំថ្នាក់ដឹកនាំថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

ផែនការសកម្មភាពខែបន្ទាប់

- សរសេររបាយការណ៍កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស
- ពិនិត្យមើសកម្មភាពក្នុងផែនការអគ្គលេខាធិការដ្ឋាន និងមូលនិធិសកល
- ត្រៀមអនុវត្តសកម្មភាពក្នុងផែនការបស់នាយកដ្ឋាន និងមូលនិធិសកល

ការចាវថិកា

ថវិកាជាតិ

ច្បាប់ថវិកា២០២០ (លានរៀល)		គ្រោងថវិកា (លានរៀល)		
ច្បាប់	វិចារណកម្មចំណាយ	២០២១	២០២២	២០២៣
6,212.00	5,510.10	5,510.10	6,464.10	6,968.10

ម្ចូលនិងិសកល

Achievement for Q2 (Apr-June), 2020

Total activities	Conducted	Postponed	%	Remarks
10 trainings (MCPI , GBV)	0	10	0%	These act to carry forward to Q3, due to CoVID-19
4 meetings (Coordination)	2	2	50%	1 already conducted on 10th Jun another due on 30th June
6 supervisions (MCPI , GBV)	6	0	100%	
Total 20	8	12	60%	

ម្ចូលនិងិសកល

- There are 9 activities:

  - 4 activities implemented

  - 5 activities postponed

  - The activities related to gathering people were not organized,

- 12 activities in Q2 carried over to Q3 that lead to total 27 activities for Q3(12+15) .
- The recruiting consultant is progress now at (announcement)

Fund Request Application (FRA) 2021-23

Description	Budget (in USD)			
	Y1	**Y2**	**Y3**	**Total**
Core Activities				
I-MCPI (Most AT risk Population Community Program Initiative and building and improving Enabling Environment)	6,770	6,770	-	13,540
II. Gender Based Violence (GBV)	8,380	8,380	-	16,760
III. CIP/CDP: This component is about to assist commune council to develop HIV AIDS plan	64,295	80,303	85,906	230,504
IV. Grant management, Administrative and Running Cost	25,146	25,346	27,346	77,838
Total	**104,591**	**120,799**	**113,252**	**338,642(334K)**
Prioritized Above Allocative Request (PAAR) FOR FIVE MORE PROVINCES				
V. CIP/CDP: This component is about to assist commune council to develop HIV/AIDS plan in their commune plans (number of commune council trained, and number of commune councils integrate HIV response in their plans).		69,235	93,352	162,587
Total	**-**	**69,235**	**93,352.00**	**162,587**
Grand total	**104,591**	**190,034**	**206,604**	**501,229**

HIV FRA: Overview of 2021-2023 Allocation

Country	**Royal Kingdom of Cambodia**
Component	**HIV**
Planned grant start date	**January 1, 2021**
Planned grant end date	**December 31, 2023**
Principal Recipient	Ministry of Economy and Finance
Currency	US Dollar
Allocation Funding Request Amount	**$41,595,706**
Prioritized Above Allocation Request (PAAR)	**$8,151,887**

Objectives

1. ***Avert new infections through tailored prevention interventions***
2. ***Intensify case detection to achieve the 1st 90.***
3. ***Ensure the 3rd 90 through quality and universal coverage along the HIV cascade of care***
4. ***Sustain a robust national response through integrative and multisectoral approaches***

HIV FR: Summary Budget by Module

Prioritized Module	Year 1 (USD)	Year 2 (USD)	Year 3 (USD)	Total (USD)	%
1. Treatment, care and support (ARVs = 28%)	7,167,611	6,104,720	4,518,858	17,791,188	43%
2. Prevention	2,268,615	2,294,111	2,266,145	6,828,871	16%
3. Differentiated HIV Testing Services	1,680,008	1,737,901	1,729,195	5,147,104	12%
4. RSSH: Health management information systems and M&E	906 363	888 316	630 782	2 425 461	6%
5. Reducing human rights-related barriers to HIV/TB services	179,379	166,065	166,669	512,113	1%
6. Program management	2,635,636	2,592,068	2,608,935	7,836,638	19%
7. RSSH: Health products management systems	105,997	141,477	148,339	395,813	1%
8. RSSH: Laboratory systems	259,433	115,104	126,876	501,413	1%
9. PMTCT	51,096	30,098	18,958	100,152	0.28%
10.TB/HIV	18,984	18,984	18,984	56,952	0.16%
Total	**15,273,121**	**14,088,845**	**12,233,740**	**41,595,706**	**100%**

HIV FR: RGC Domestic Co-financing Commitments for HIV

RGC Commitments	Current Allocation Period (in million USD)				FRA Allocation Period (in million USD)			
	2018	2019	2020	Total	2021	2022	2023	Total
ARVs	1.5	1.5	1.5	4.5	2.5	3.5	5	**11**
Other (staff, goods, services)	1.38	1.7	1.8	4.9	4.8	1.9	1.95	**8.7**
Total	**2.9**	**3.2**	**3.4**	**9.45**	**7.3**	**5.4**	**6.95**	**19.7**



Total HIV and ARV RGC co-financing commitments (MoEF, MoH)



Percent funding for ARVs by RGC and GF, Cambodia 2011-2023

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ខែមិថុនា

- បានបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកល
- បញ្ចប់ការបកប្រែជាភាសាជាតិ នៃឯកសារយុទ្ធសាស្ត្រជាតិជាពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ ឆ្នាំ២០១៩-២០២៣
- សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាបច្ចេកទេស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បំណែងចែកមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ទទួលបន្ទុកសម្របសម្រួល សហការជាមួយអង្គការធ្វើការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងប្រទេសកម្ពុជា
- បានឯកភាពលើការផ្តួចផ្តើមនៃការបន្តសិក្សាស្ថានភាព និងទស្សនទាននៃការឆ្លើយតបមេរោគអេដស៍ នៅកម្ពុជា ឆ្នាំ២០១៩-២០២៥ (Overview of situation on HIV Response in Cambodia 2019-2025)
- ផលិតឯកសារគោល "ការឆ្លើយតបប្រកបដោយចីរភាព ឈានទៅបញ្ចប់អេដស៍ ជាការគំរាមដល់សុខភាពសាធារណៈ ត្រឹមឆ្នាំ២០២៥" សម្រាប់តម្រង់ទិសគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត
- វគ្គបណ្តុះបណ្តាលស្តីពីសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមរបស់ក្រសួងមហាផ្ទៃ
- វគ្គបណ្តុះបណ្តាលស្តីពីបុរសរួមភេទជាមួយបុរស
- បទបង្ហាញអង្គការ FHI360 ស្តីពី CamBlitz និង NCHADS Social Media Accomplishments

- បច្ចុប្បន្នភាពនៃអន្តរាគមន៍បង្ការមេរោគអេដស៍ និងជំងឺអេដស៍លើក្រុមប្រឈមមុខ ភាពជោគជ័យ ការប្រឈមមេរៀនបទពិសោធន៍ និងទិសដៅ របស់អង្គការ KHANA
- ការចូលរួមរបស់សហគមន៍ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
- ចេញលិខិតដល់គណៈអភិបាល រាជធានីខេត្ត ឱ្យធ្វើអន្តរាគមន៍ និងសម្របសម្រួលឱ្យមានការបញ្ចូលសកម្មភាព និងថវិកាឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក និងថ្នាក់ឃុំ សង្កាត់ដែលជាគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅជុំវិញខេត្ត។

៤. បញ្ហា និងការប្រឈម

- ស្ថានភាពជំងឺកូវីដ១៩ នៅតែផលប៉ះពាល់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
- មិនទាន់សុខដុមលើការបចញ្ចូលទិន្នន័យក្នុងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២១-២០២៣
- ចំនួនប្រជាជនប្រឈម (KP) មានចំនួនកើនឡើង ហើយអត្រាប្រែ៉ាឡង់ក៏ខ្ពស់
- ចំនួនឆ្លងថ្មីនៅតែមានខ្ពស់ ជាពិសេសក្រុមបុរសរួមភេទជាមួយបុរស
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ថ្នាក់នៅមិនទាន់បានយល់ច្បាស់រចនាសម្ព័ន្ធ និងតួនាទីដែលបានចែងក្នុងអនុក្រឹត្យ១០៩ និង ស.ជ.ណ២១៣
- ការធ្វើសមាហរណកម្មកម្មវិធីអេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ឃុំ សង្កាត់
- ការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- ការផ្តល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍នៅមានកម្រិតទាបខ្លាំង
- គម្លាតធនធានថវិកា (resource gap) សម្រាប់យុទ្ធសាស្ត្រឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅតែជាកង្វល់
- ការអនុវត្តសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ រវាងរដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូរួមជាមួយសង្គមស៊ីវិល និងបណ្តាញការងារអេដស៍នៅមិនទាន់មានសុខដុម និងប្រទាក់ក្រឡាគ្នានៅឡើយ

៥. ជំហានបន្ត សម្រាប់ខៃបន្ទាប់

- ចុះអនុវត្តការធ្វើសមាហរណកម្មកម្មវិធីអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ឃុំ ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។
- បញ្ជូនលិខិតផ្លូវការទៅក្រសួងសុខាភិបាល ដើម្បីផ្តល់យោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកល។
- ចេញលិខិតដល់គណៈអភិបាល រាជធានីខេត្ត ឱ្យធ្វើអន្តរាគមន៍ និងសម្របសម្រួលឱ្យរៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ស្រុក ខណ្ឌ ក្រុង ឃុំ សង្កាត់។
- "ការឆ្លើយតបប្រកបដោយចីរភាព ឈានទៅបញ្ចប់អេដស៍ ជាការគំរាមដល់សុខភាពសាធារណៈ ត្រឹមឆ្នាំ ២០២៥" សម្រាប់តម្រង់ទិសគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត។
- ជំរុញអនុវត្តគំនិតផ្តួចផ្តើមទីក្រុងដែលពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ (Fast Tract City Initiative)។
- បន្តសិក្សាស្ថានភាព និងទស្សនទាននៃការឆ្លើយតបមេរោគអេដស៍ នៅកម្ពុជា ឆ្នាំ២០១៩-២០២៥ (Overview of situation on HIV Response in Cambodia 2019-2025)។
- បន្តជំរុញការផ្តល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍ឆ្ពោះទៅសម្រេចវិធានការទី២។
- ជំរុញអនុវត្ត ស.ជ.ណ ២១៣ អំពីការដាក់វិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

- ជំរុញការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- ពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវសុខដុមនីយកម្ម និងភាពប្រទាក់ក្រឡាគ្នា លើការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍រដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូ រួមជាមួយសង្គមស៊ីវិល និងបណ្តាញការងារអេដស៍។
- ពង្រឹងការសម្របសម្រួលជាមួយដៃគូ និងសង្គមស៊ីវិលលើការងារឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍។
- បន្តអន្តរគមន៍ផ្សព្វផ្សាយអប់រំដល់ក្រុមប្រឈម ជាពិសេសក្រុមបុរសរួមភេទជាមួយបុរស។
- បើកវគ្គបណ្តុះបណ្តាលផ្ទៃក្នុងសម្រាប់ពង្រឹងសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋាន។
- ត្រៀមរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២០។
- ត្រៀមរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៦ ឆ្នាំ២០២០។
- បំពេញកិច្ចការផ្សេងៗទៀត តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ ។

សូមអរគុណ!